**សុន្ទរកថារបស់**

**ឯកឧត្តម ឱក ធីណា អនុរដ្ឋលេខាក្រសួងពាណិជ្ជកម្ម**

**ថ្លែងក្នុងឱកាស បើកសិក្ខាសាលា**

**ស្តីពី**

**ការផ្សព្វផ្សាយកម្មវិធីអភិក្រមគ្របដណ្តប់វិស័យពាណិជ្ជកម្ម**

(Trade SWAp Awareness Workshop)

**នៅទីរួមខេត្តមណ្ឌលគិរី, ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១២**

សូមគោរព ឯកឧត្តម **ច៉ាង ហមផាន** អភិបាលខេត្តមណ្ឌលគីរី ជាទីគោរព

លោក Julian Clarke ជាតំណាង ធនាគារពិភពលោក, ….

ឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិក សមាជិការ នៃអង្គសិក្ខាសាលាជាទីមេត្រី

ថ្ងៃនេះខ្ញុំមានកិត្តិយស និងមានសេចក្តីរីករាយយ៉ាងក្រៃលែង ដែលបានមកចូលរួមជាអធិបតី ក្នុងពិធីបើកសិក្ខាសាលា ស្តីពី "ការផ្សព្វផ្សាយកម្មវិធីអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម" ដ៏មានសារសំខាន់នេះ លើទឹកដីដ៏ស្រស់បំព្រងនៃខេត្ត **មណ្ឌលគិរី** ។ ក្នុងនាម **ឯកឧត្តម បណ្ឌិត ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសំដែងការស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានរបស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលបានអញ្ជើញមកចូលរួមយ៉ាងកុះករនៅក្នុងអង្គសិក្ខាសាលានេះ ហើយឆ្លៀតឱកាសនេះផងដែរ ខ្ញុំសូមថ្លែងអំណរគុណចំពោះតំណាងធនាគារពិភពលោក (WB), និង ម្ចាស់ជំនួយ រួមមាន: សហគមន៍អឺរ៉ុប (EU), ទីភ្នាក់ងារអភិវឌ្ឍន៍ប្រទេសដាណឺម៉ាក (DANIDA), អង្គការ UNIDO ព្រមទាំងដៃគូរអភិវឌ្ឍន៍នានា (DPs) ដែលបានចូលរួម និងផ្តល់ជំនួយហិរញ្ញប្បទានដល់ប្រទេសកម្ពុជា ដើម្បីជួយអនុវត្តន៍កម្មវិធីអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម (Trade Sector Wide Approach ហៅកាត់ថា Trade SWAp) តាមរយៈការជួយគាំទ្រដល់ "កម្មវិធីគាំទ្រការអភិវឌ្ឍន៍ពាណិជ្ជកម្ម (Trade Develoment Support Program-TDSP)" និងតាមរយៈ ការជួយគាំទ្រដល់ "គម្រោងពង្រឹងសមាហរណកម្មពាណិជ្ជកម្ម ( Enhanced Integrated Framework-EIF)" ។

ខ្ញុំក៏ឆ្លៀតយកឱកាសនេះសូមថ្លែង នូវការកោតសរសើរដល់មន្ត្រី គ្រប់ជាន់ថ្នាក់របស់

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នៃអគ្គនាយកពាណិជ្ជកម្មអន្តរជាតិ នៃក្រសួងពាណិជ្ជកម្ម ដែលបានសហការជាមួយអាជ្ញាធរដែនដី និង មន្ទីរពាណិជ្ជកម្មខេត្តមណ្ឌលគិរី រៀបចំចាត់ចែងសិក្ខាសាលា ស្តីអំពី "ការផ្សព្វផ្សាយកម្មវិធី អភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម" នេះឲ្យកើតចេញជារូបរាងឡើង ។

អនុញ្ញាតិឲ្យខ្ញុំជម្រាបអង្គសិក្ខាសាលា អំពីប្រវត្តិសង្ខេប របស់កម្មវិធីគាំទ្រការអភិវឌ្ឍន៍ពាណិជ្ជកម្ម (TDSP) ដែលជាប្រធានបទគោលនៃសិក្ខាសាលាថ្ងៃនេះ ។ រាជរដ្ឋាភិបាលកម្ពុជាបានប្រគល់ភារកិច្ចជូនក្រសួងពាណិជ្ជកម្មក្នុងការដឹកនាំ និងសម្របសម្រួលការងារអភិវឌ្ឍន៍ក្នុងវិស័យពាណិជ្ជកម្ម ។ អភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម (Trade SWAp) ត្រូវបានរាជរដ្ឋាភិបាលអនុម័តឲ្យអនុវត្តជាផ្លូវការកាលពី ដើមឆ្នាំ ២០០៨ ។ អភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម គឺជាយន្តការមួយដ៏សំខាន់មួយរបស់រាជរដ្ឋាភិបាល ដែលមានគោលដៅជាចម្បងក្នុងការអភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម, កាត់បន្ថយភាពក្រីក្រ, និងជម្រុញកំណើនសេដ្ឋកិច្ចប្រកបដោយចេរភាព ។ ដើម្បីឈានទៅសម្រេចគោលដៅនេះ កាលពីថ្ងៃទី ១៤ កុម្ភៈ ២០០៩ រាជរដ្ឋាភិបាលកម្ពុជាបានចុះកិច្ចព្រមព្រៀងទទួលជំនួយឥតសំណងចំនួន US$12.35 លានដុល្លា សម្រាប់ប្រើប្រាស់ក្នុងរយៈ ៣ ឆ្នាំ ដើម្បីអនុវត្តកម្មវិធី TDSP សំដៅជួយប្រទេសកម្ពុជា ក្នុងការកសាងគោលនយោបាយពាណិជ្ជកម្ម ហើយធ្វើការអនុវត្តន៍ឲ្យបានសមស្រប នូវគោលនយោបាយទាំងនោះ ។ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ត្រូវបានជ្រើសរើសជាលេខាធិការដ្ឋានរបស់ Trade SWAp និងភ្នាក់ងារប្រតិបត្តិ (Executing Agency) នៃកម្មវិធី TDSP ។

លទ្ធផលនៃការវាយតម្លៃ របស់បេសកកម្មត្រួតពិនិត្យរបស់ធនាគារពិភពលោក បានទទួលស្គាល់ថា ការអនុវត្តគម្រោង TDSP ក្នុងឆ្នាំ ២០១១ ទទួលបានលទ្ធផលគួរជាទីពេញចិត្ត (Satisfactory Level) ហើយគម្រោង TDSP ត្រូវបានគេបន្តឲ្យអនុវត្តជាផ្លូវការ ចំនួន ២២ ខែ បន្តទៀត គឺរហូតដល់ថ្ងៃទី ៣១ មករា ២០១៤ ។

ដោយឡែកការអនុវត្តន៍ "គម្រោងពង្រឹងសមាហរណកម្មពាណិជ្ជកម្ម ( Enhanced Integrated Framework-EIF)" ក៏ទទួលបានលទ្ធផលគួរឲ្យកត់សំគាល់ផងដែរ ហើយតាមរយៈលទ្ធផលនេះ មានប្រទេសមួយចំនួនបានចុះមកធ្វើការសិក្សាស្រាវជ្រាវ ដកបទពិសោធពីការអភិវឌ្ឍន៍វិស័យពាណិជ្ជកម្មនៅកម្ពុជា ។ កាលពីឆ្នាំ ២០១១ ប្រទេស ណេប៉ាល់ បាន

មកធ្វើទស្សនៈកិច្ចសិក្សានៅកម្ពុជា ហើយនៅចុងខែ មិថុនា ២០១២ ខាងមុខនេះ ប្រទេស Bangladesh នឹងមកធ្វើទស្សនៈកិច្ចសិក្សានៅកម្ពុជា ។

អាស្រ័យហេតុនេះ ដើម្បីស្វែងយល់ថាកម្មវិធី TDSP មានសកម្មភាព និងមានអត្ថប្រយោជន៍បែបណាខ្លះនៅក្នុងវិស័យពាណិជ្ជកម្ម ក៏ដូចជាវិស័យសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ខ្ញុំសូមឲ្យលោក លោកស្រី ទាំងអស់មេត្តាយកចិត្តទុកដាក់ចូលរួមស្តាប់ និងលើកឡើងពល់ចម្ងល់នានា ដែលទាក់ទងនឹងកម្មវិធី TDSP និង Trade SWAp ឲ្យបានផុសផុលដើម្បីជាបច្ច័យផ្តល់លទ្ធភាពដល់លោក លោកស្រី ក្នុងការចូលរួមអនុវត្តន៍ និងប្រើប្រាស់មូលនិធិដែលមានស្រាប់នេះឲ្យកាន់តែមានប្រសិទ្ធភាព ។

ជាការចាប់ផ្តើមកម្មវិធីរយៈពេលមួយថ្ងៃពេញនេះ ខ្ញុំសូមប្រកាសបើកសិក្ខាសាលាជាផ្លូវការ និង សូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រកបទៅដោយជោគជ័យ និងផ្លែផ្កាពីសិក្ខាសាលាថ្ងៃនេះ ។